ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៧៦
ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ: ១៧៥
ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣
សាលក្រមលេខ: ៣៤ "ខ"/៣៤៤
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តសៀមរាប បានបើកសវនាការជាសាធារណៈ
នៅសាលសវនាការលេខ ក១ នៃសាលាដំបូងខេត្តសៀមរាប
កាលបរិច្ឆេទបើកសវនាការថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ វេលាព្រឹក។
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ វេលាព្រឹក។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាអនុប្រធានសាលាដំបូង

**តំណាងអយ្យការ**

លោកស្រី [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៧៦ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ និងសំណុំរឿងជំនុំជម្រះលេខ: ១៧៥ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១- ឈ្មោះ [redacted] (**ឡៀម ចាំ**) ភេទប្រុស អាយុ ៤៧ ឆ្នាំ (កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧២) ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី២ ប្រពន្ធឈ្មោះ [redacted] សុាំ (រ) មានកូន ០៣នាក់ ឪពុកឈ្មោះ [redacted] ចៀប (ស) ម្តាយឈ្មោះ [redacted] ព៉ាន់ (ស) ទោសពីមុនគ្មាន ។ **(ក្នុងឃុំ)**

**- ឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ។**

**- ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៤៩ ឃខ/ឈ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៣ ។**

២- ឈ្មោះ [redacted] **សិទ្ធ** ភេទប្រុស អាយុ ២៧ ឆ្នាំ (កើតថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ១៩៩៦) ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅមុនពេលឃាត់ខ្លួននៅភូមិដូនន់ ឃុំមានជ័យ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី៥ ប្រពន្ធឈ្មោះ [redacted] ស្រីពេជ្រ (រ) មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] សង (រ) ម្តាយឈ្មោះ [redacted] សុង (រ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ២ឆ្នាំ ពីបទល្មើសគ្រឿងញៀន ។ **(ក្នុងឃុំ)**

- ឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ។

- ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ៥០ ឃខ/ឈ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ។

ត្រូវជាប់ចោទពីបទៈ **នេសាទត្រីដោយប្រើឧបករណ៍ឆក់** ប្រព្រឹត្តនៅចំណុចនិយាមកាកោះត្រឡាច ភូមិឃុនមោឃ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៨ ចំណុច ៤ នៃច្បាប់ស្តីពីជលផល។

- ដោយមានលោក [redacted] មានអាសយដ្ឋាននៅការិយាល័យក្រុមមេធាវីអាស៊ីកម្ពុជា ស្ថិតនៅវីឡាលេខ ៦៤ ផ្លូវលេខ ៥៩២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងពីរនាក់។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៥៨ អយធ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ១១៥៧ ពស.ព្រស/ឈ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១៨២ ពស.ព្រជ (ក) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

**ឯអង្គហេតុកើតមានឡើងដូចតទៅ**

កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ១រំលងអាធ្រាត្រ ស្ថិតនៅចំណុចនិយាមកាកោះត្រឡាច ភូមិឃុនមោឃ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានករណីនេសាទត្រីដោយប្រើឧបករណ៍ឆក់ បង្កឡើងដោយជនជាប់ចោទឈ្មោះ[redacted] ចាំ ([redacted] ចាំ) ភេទប្រុស អាយុ ៤៧ ឆ្នាំ និងឈ្មោះ[redacted] សិទ្ធ ភេទប្រុស អាយុ ២៧ ឆ្នាំ។ ក្រោយពីពួកគេបានឆក់ត្រីរួច បានជិះម៉ូតូត្រឡប់ទៅផ្ទះវិញ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងបានដកហូតនូវឧបករណ៍ឆក់ត្រីមួយចំនួនរួមមាន អាំងវែកទ័រឆក់ត្រីមានខ្សែភ្លើងចំនួន ០១ គ្រឿង, អាគុយ ៤០ អំពែចំនួន ០១ គ្រឿង, ត្រីឆក់បានចំនួន ៣គីឡូក្រាម និងម៉ូតូមួយគ្រឿងម៉ាក HONDA DREAM ស៊េរីឆ្នាំ២០១៣ ពណ៌ខ្មៅ ស្លាកលេខ សៀមរាប 1O-4197 ។ ក្រោយពីសមត្ថកិច្ចឃាត់ខ្លួន និងដកហូតវត្ថុតាងខាងលើនេះរួចមក សមត្ថកិច្ចបានសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាំ ([redacted] ចាំ) និងឈ្មោះ [redacted] សិទ្ធ បានឆ្លើយសារភាពថា ពួកគេពិតជាបានទៅឆក់ត្រីនៅវេលាម៉ោង ៨យប់ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ស្ថិតនៅចំណុចទំនប់៧៨ ស្ថិតនៅភូមិឃុនមោឃ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប លុះដល់ម៉ោង១រំលងអាធ្រាត្រ ពួកគេបានត្រឡប់មកផ្ទះវិញ នៅពេលធ្វើដំណើរតាមផ្លូវក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងដកហូតវត្ថុតាងតែម្តង។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ[redacted] ចាំ ([redacted] ចាំ) បានឆ្លើយថា ៖ ខ្លួនសុំទទួលស្គាល់ និងរក្សាចម្លើយនៅដំណាក់កាលអយ្យការ និងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ទុកជាបានការដដែល។ សមត្ថកិច្ច



Scanned with CamScanner

ឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ១រំលងអាធ្រាត្រ ស្ថិតនៅចំណុចកោះត្រឡាច ភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបាន អាំងវែកទ័រឆក់ត្រីមានខ្សែភ្លើងចំនួន ០១ គ្រឿង, អាគុយ ៤០ អំពែចំនួន ០១ គ្រឿង, ត្រីឆក់បានចំនួន៣គីឡូក្រាម និងម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០១៣។ មូលហេតុដែលសមត្ថកិច្ចឃាត់ខ្លួន ដោយសារខ្លួនបានទៅឆក់ត្រីនៅចំណុចចុងស្រែទំនប់៧៨ ស្ថិតនៅភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ខ្លួនពិតជាបានជិះម៉ូតូទៅឆក់ត្រីនៅវេលាម៉ោង៨យប់ ទៅជាមួយប្អូនថ្លៃឈ្មោះ [redacted] សិទ្ធ ហេតុដល់ម៉ោង ១រំលងអាធ្រាត្រ ខ្លួន និងឈ្មោះ [redacted] សិទ្ធ បានជិះម៉ូតូត្រឡប់ទៅផ្ទះវិញ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនឆក់ត្រីបានចំនួន ៣គីឡូក្រាម។ ខ្លួនទៅឆក់ត្រី គឺដើម្បីយកទៅដោះស្រាយជីវភាពគ្រួសារប៉ុណ្ណោះ មិនបានយកទៅលក់ដូរ ឬធ្វើអាជីវកម្មទេ។ ខ្លួនធ្លាប់ឆក់ត្រីបានចំនួន២លើក។ សូមឲ្យតុលាការជួយសម្រាលទោសដល់ខ្លួនផង ខ្លួនបានដឹងកំហុសហើយ។

- ជនជាប់ចោទឈ្មោះ [redacted] **សិទ្ធ** បានឆ្លើយថា ៖ ខ្លួនសុំទទួលស្គាល់ និងរក្សាចម្លើយនៅដំណាក់កាលអយ្យការ និងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ទុកជាបានការដដែល។ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២៣ វេលាម៉ោង១រំលងអាធ្រាត្រ ស្ថិតនៅចំណុចកោះត្រឡាច ភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបាន អាំងវែកទ័រឆក់ត្រីមានខ្សែភ្លើងចំនួន ០១ គ្រឿង, អាគុយ ៤០ អំពែចំនួន ០១ គ្រឿង, ត្រីឆក់បានចំនួន ៣គីឡូក្រាម និងម៉ូតូ ១គ្រឿងម៉ាក ហុងដាឌ្រីម ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣។ មូលហេតុដែលសមត្ថកិច្ចឃាត់ខ្លួន ដោយសារខ្លួនបានទៅឆក់ត្រីនៅចំណុចចុងស្រែទំនប់៧៨ ស្ថិតនៅភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ខ្លួនពិតជាបានជិះម៉ូតូទៅឆក់ត្រីនៅវេលាម៉ោង ៨យប់ ទៅជាមួយបងថ្លៃឈ្មោះ [redacted] ចាំ ហេតុដល់ម៉ោង ១រំលងអាធ្រាត្រ ខ្លួន និងឈ្មោះ [redacted] ចាំ បានជិះម៉ូតូត្រឡប់ទៅផ្ទះវិញ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនឆក់ត្រីបានចំនួន៣គីឡូក្រាម។ ខ្លួនទៅឆក់ត្រី គឺដើម្បីយកទៅដោះស្រាយជីវភាពគ្រួសារប៉ុណ្ណោះ មិនបានយកទៅលក់ដូរ ឬធ្វើអាជីវកម្មទេ។ ខ្លួនធ្លាប់ឆក់ត្រីបានចំនួន២លើកមកហើយ។ សូមឲ្យតុលាការជួយសម្រាលទោសដល់ខ្លួនផង ខ្លួនបានដឹងកំហុសហើយ ។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **និចឡុន** ជាមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយបញ្ជាក់នៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ នៅវេលាម៉ោងប្រហែល ៨ និង ៣០នាទីយប់ កម្លាំងរបស់ខ្លួនមានគ្នាចំនួន១០នាក់ ដែលដឹកនាំ និងបញ្ជាដោយលោកវរសេនីយ៍ទោ [redacted] ប៊ុនរ៉ុង អធិការរងស្រុកប្រាសាទបាគង ទទួលបន្ទុកការងារប្រឆាំងបទល្មើសគ្រឿងញៀន បានចុះទៅទប់ស្កាត់ និងបង្ក្រាបបទល្មើសនៅក្នុងភូមិសាស្ត្រស្រុកប្រាសាទបាគង និងចំណុចនិយាមកាកោះត្រឡាច ភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ នៅពេលចុះទៅដល់ទីតាំងកន្លែងកើតហេតុនៅវេលាម៉ោងប្រហែល១រំលងអាធ្រាត្រ ឈានចូលថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ក៏ប្រទះឃើញជនជាប់ចោទពីរនាក់ឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ជិះម៉ូតូឌុបគ្នាពីទិសដៅពីត្បូង ហើយកម្លាំងរបស់ខ្លួនក៏បានធ្វើការឃាត់ខ្លួន ត្រួតពិនិត្យ និងឆែកឆេរក៏ឃើញមានឧបករណ៍ឆក់, អាគុយ, អាំង-

Scanned with CamScanner

វែកទ័រ និងត្រីចម្រុះប្រហែល៣គីឡូក្រាម ហើយកម្លាំងរបស់ខ្លួនបានបញ្ជូនជនទាំងពីរនាក់ខាងលើទៅអធិការនគរបាលស្រុកប្រាសាទបាគង ដើម្បីធ្វើការសួរនាំ និងបានដកហូតវត្ថុតាងរួមមាន ម៉ូតូម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០១៣ ផ្លាកលេខ សៀមរាប 1O-4197 ចំនួន១គ្រឿង, អាំងវែកទ័រឆក់ត្រី ចំនួន ១គ្រឿង, អាគុយ ៤០អំពែ ចំនួន ១គ្រឿង និងត្រីចំនួន ៣គីឡូក្រាម ហើយសមត្ថកិច្ចបានធ្វើតេស្តពិនិត្យទឹកនោមរកសារធាតុទាំង២នាក់ លទ្ធផលអវិជ្ជមានទាំងពីរនាក់។ បន្ទាប់ពីធ្វើការឃាត់ខ្លួន និងសាកសួរលើឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ព្រមទាំងដកហូតវត្ថុតាងរួចមក ក៏បានប្រគល់ជនជាប់ចោទទាំងពីរនាក់នេះ ទៅឲ្យមន្ត្រីជំនាញការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ចខេត្តសៀមរាប ហើយការិយា-ល័យប្រឆាំងបទល្មើសសេដ្ឋកិច្ចបានប្រគល់ជនទាំងពីរខាងលើបន្តឲ្យទៅខណ្ឌរដ្ឋបាលជលផលសៀមរាប ដើម្បីអនុវត្តនីតិវិធីបន្ត។ និយាមការកោះត្រឡាច ស្ថិតនៅភូមិយុនមោយ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ជាវាលស្រែ និងជាឃ្លាំងទប់ទឹកសម្រាប់ធ្វើស្រែប្រាំង ដោយកន្លែងឆក់នោះមានជម្រៅប្រហែលត្រឹមជង្គង់ ហើយទីតាំងនោះឧស្សាហ៍មានបទល្មើសនេសាទត្រីដោយឧបករណ៍ឆក់កើតឡើងជាញឹកញាប់ផងដែរ។ ចំពោះអាកប្បកិរិយារបស់ជនជាប់ចោទឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ជាមនុស្សស្លូតត្រង់ យោងតាមបទពិសោធន៍ និងតាមការអង្កេតរបស់ខ្លួន ឃើញថា ពួកគាត់ទាំងពីរនាក់ខាងលើនេះ មិនមែនជាអ្នកឆក់ត្រីអាជីពដើម្បីយកត្រីទៅលក់ទេ គឺពួកគាត់គ្រាន់តែឆក់ត្រីយកទៅដោះស្រាយជីវភាពគ្រួសារប៉ុណ្ណោះ។ ចំពោះស្ថានភាពគ្រួសាររបស់ពួកគាត់ទាំងពីរនាក់ខាងលើ មានជីវភាពមធ្យម ដោយឈ្មោះ [redacted] ចាំ ជាជាងជុសជុលម៉ូតូ នៅក្នុងភូមិ។ ខ្លួនសូមសំណូមពរឲ្យតុលាការបន្ធូរបន្ថយទោសដល់ពួកគាត់ផង។

- តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ខ៊ាន់ដែន** ជាមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយបញ្ជាក់នៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ នៅវេលាម៉ោងប្រហែល ៨ និង ៣០នាទីយប់ កម្លាំងរបស់ពួកខ្លួនមានគ្នាចំនួន ១០នាក់ ដែលដឹកនាំ និងបញ្ជាដោយលោកវរសេនីយ៍ទោ [redacted] ប៊ុនរ៉ុង អធិការរងស្រុកប្រាសាទបាគង ទទួលបន្ទុកការងារប្រឆាំងបទល្មើសគ្រឿងញៀន បានចុះទៅទប់ស្កាត់ និងបង្រ្កាបបទល្មើសនៅក្នុងភូមិសាស្ត្រស្រុកប្រាសាទបាគង និងចំណុចនិយាមកាកោះត្រឡាច ភូមិយុនមោយ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ នៅពេលចុះទៅដល់ទីតាំងកន្លែងកើតហេតុ នៅវេលាម៉ោងប្រហែល១រំលងអាធ្រាត្រ ឈានចូលថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ក៏ប្រទះឃើញជនជាប់ចោទពីរនាក់ឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ជិះម៉ូតូឌុបគ្នាពីទិសដៅពីត្បូង ហើយកម្លាំងរបស់ខ្លួនក៏បានធ្វើការឃាត់ខ្លួន ត្រួតពិនិត្យ និងឆែកឆេរឃើញមានឧបករណ៍ឆក់, អាគុយ, អាំងវែកទ័រ និងត្រីចម្រុះប្រហែល៣គីឡូក្រាម ហើយកម្លាំងរបស់ខ្លួនបានបញ្ជូនជនទាំងពីរនាក់ខាងលើ ទៅអធិការនគរបាលស្រុកប្រាសាទបាគង ដើម្បីធ្វើការសួរនាំ និងបានដកហូតវត្ថុតាងរួមមាន ម៉ូតូម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៣ ផ្លាកលេខ សៀមរាប 1O-4197 ចំនួន ១គ្រឿង, អាំងវែកទ័រឆក់ត្រី ចំនួន ១គ្រឿង, អាគុយ ៤០អំពែ ចំនួន១គ្រឿង និងត្រីចំនួន៣គីឡូក្រាម ហើយសមត្ថកិច្ចបានធ្វើតេស្តពិនិត្យទឹកនោមរកសារធាតុទាំងពីរនាក់ លទ្ធផលអវិជ្ជមានទាំងពីរនាក់។ បន្ទាប់ពីធ្វើការឃាត់

ខ្លួន និងសាកសួរលើឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ព្រមទាំងដកហូតវត្ថុតាងរួចមក ក៏បានប្រគល់ជនជាប់ចោទទាំងពីរនាក់នេះទៅឲ្យមន្ត្រីជំនាញការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ចខេត្តសៀមរាប ហើយការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ចបានប្រគល់ជនទាំងពីរខាងលើបន្តឲ្យទៅខណ្ឌរដ្ឋបាលជលផលសៀមរាប ដើម្បីអនុវត្តនីតិវិធីបន្ត។ និយាមការកោះត្រឡាច ស្ថិតនៅភូមិយុនមោយ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ជាវាលស្រែ និងជាឃ្លាំងទប់ទឹកសម្រាប់ធ្វើស្រែប្រាំង ដោយកន្លែងឆក់នោះមានជម្រៅប្រហែលត្រឹមជង្គង់ ចំពោះទីតាំងខាងលើគឺឧស្សាហ៍មានបទល្មើសនេសាទដោយឧបករណ៍ឆក់កើតឡើងជាញឹកញាប់ផងដែរ ហើយកម្លាំងសមត្ថកិច្ចឧស្សាហ៍ចុះទៅបង្ក្រាបជាញឹកញាប់នៅទីតាំងខាងលើនេះផងដែរ តែពុំសូវចាប់ជនល្មើសបាននោះទេ ដោយសារជនល្មើសបានដឹងខ្លួនមុន។ ទីតាំងចំណុចកើតហេតុខាងលើនេះនៅឆ្ងាយពីភូមិប្រហែល១០គីឡូម៉ែត្រ ជាកន្លែងដែលស្ងាត់។ សកម្មភាពឆក់ត្រីនៅចំណុចខាងលើនេះភាគច្រើននៅពេលយប់ស្ងាត់។ ចំពោះអាកប្បកិរិយារបស់ជនជាប់ចោទឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ជាមនុស្សស្លូតត្រង់មិនប្រចេងប្រចាង ឬរឹងទទឹងអ្វីទេ។ ខ្លួនពុំដឹងថាឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ធ្វើសកម្មភាពឆក់ត្រីនៅចំណុចកើតហេតុខាងលើនេះប៉ុន្មានដងទេ តែតាមចម្លើយរបស់ពួកគាត់បានឆ្លើយសារភាពថាបានឆក់ប្រហែល៦លើក ហើយឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ បានឆ្លើយបន្តទៀតថា គឺពួកគាត់គ្រាន់តែឆក់ត្រីយកទៅដោះស្រាយជីវភាពគ្រួសាររបស់ពួកគាត់តែប៉ុណ្ណោះ។ ចំពោះស្ថានភាពគ្រួសាររបស់ពួកគាត់ទាំងពីរនាក់ខាងលើ ខ្លួនពុំដឹងនោះទេ។ ខ្លួនសូមសំណូមពរឲ្យតុលាការសម្រេចតាមច្បាប់។

- សាក្សីឈ្មោះ [redacted] **មណ្ណរដេត** ជាមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយបញ្ជាក់ថា៖ ចំពោះរឿងហេតុពាក់ព័ន្ធនឹងឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ដំបូងឡើយជនទាំងពីរនាក់នេះត្រូវបានកម្លាំងអធិការនគរបាលស្រុកប្រាសាទបាគង ឃាត់ខ្លួនពាក់ព័ន្ធនឹងករណីឆក់ត្រី នៅចំណុចនិយាមការកោះត្រឡាច ភូមិយុនមោយ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ បានដកហូតវត្ថុតាងរួមមាន អាំងវែកទ័រឆក់ត្រី ចំនួន ១គ្រឿង, អាគុយ ៤០អំពែ ចំនួន ១គ្រឿង, ត្រីឆក់បានចំនួនប្រហែល ៣គីឡូក្រាម និងម៉ូតូចំនួន ១គ្រឿង។ ក្រោយពីឃាត់ខ្លួនលើឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ ព្រមទាំងដកហូតវត្ថុតាងរួចមក កម្លាំងសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកប្រាសាទ-បាគង បានប្រគល់ជនទាំងពីរនាក់ ទៅឲ្យមន្ត្រីជំនាញនៃខណ្ឌរដ្ឋបាលជលផលសៀមរាប ដើម្បីអនុវត្តនីតិវិធីបន្ត។ សូមបញ្ជាក់ថា ម៉ូតូដែលសមត្ថកិច្ចដកហូតបានមាន ម៉ាកហុងដាឌ្រីម សេរី២០១៣ ពណ៌ខ្មៅផ្លាកលេខ សៀមរាប 1០-4197 បច្ចុប្បន្ននេះ ត្រូវបានរក្សាទុកនៅខណ្ឌរដ្ឋបាលជលផលសៀមរាប រីឯត្រីចំនួនប្រហែល៣គីឡូក្រាម ដែលសមត្ថកិច្ចដកហូតបាន គឺខូចគុណភាព។ ទីតាំងនិយាមការកោះត្រឡាច ស្ថិតនៅភូមិយុនមោយ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ពុំសូវមានបទល្មើសកើតឡើងច្រើនទេ។ ចំពោះទីតាំងទឹកជ្រៅ ឬរាក់ខ្លួនពុំដឹងទេ។ ចំពោះសីលធម៌របស់ឈ្មោះ ចៀម ចាំ និងឈ្មោះ ឡែម សិទ្ធ មានអត្តចរិកស្លូតបូតជម្មតា មិនកាចសាហាវទេ។ តាមការសង្កេត និងបទពិសោធន៍របស់ខ្លួននាពេលកន្លងមក ពួកគាត់ទាំងពីរនាក់ខាងលើនេះមិនមែនជាអ្នកឆក់ត្រីអាជីពទេ បើសិនពួកគាត់ជាអ្នក

ឆក់ត្រីអាជីព គឺប្រើពេលវេលាដូចគ្នា គាត់នឹងឆក់បានត្រីច្រើនជាងហ្នឹង ហើយមិនអាចធ្វើការឃាត់ខ្លួន ឬចាប់ខ្លួនពួកគាត់បានទេ។ ចំពោះស្ថានភាពគ្រួសាររបស់ឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ មានជីវភាពក្រលំបាក។

**សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ**

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំថា៖ តម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ លេខៈ ១៥៨ អយធ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ទុកជាបានការដដែល និងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ**

- លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងពីរនាក់ បានសន្និដ្ឋានការពារថា៖ ក្នុងរឿងនេះកូនក្តីខ្លួនទាំង២នាក់បានឆ្លើយសារភាពថា ពិតជាបាននេសាទដោយប្រើឧបករណ៍ឆក់ប្រាកដមែន ដោយបានត្រីត្រឹម៣គីឡូក្រាមសម្រាប់ជីវភាពប្រចាំថ្ងៃ មិនបានឆក់ជាលក្ខណៈអាជីពទេ កូនក្តីខ្លួនរៀនសូត្របានតិចតួច ខ្វះការយល់ដឹង មានជីវភាពក្រីក្រ ហើយសារភាពទទួលស្គាល់កំហុស សន្យាថានឹងឈប់ប្រព្រឹត្តអំពើនេះទៀតហើយ។ ហេតុនេះសូមតុលាការពិចារណាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួន ដោយអនុវត្តទោសក្នុងពន្ធនាគារត្រឹម ៦ខែ និងព្យួរទោសដែលនៅសល់ដោយអនុគ្រោះ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

- ជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សូមតុលាការជួយសម្រាលទោសដល់ខ្លួនផង ខ្លួនបានដឹងកំហុស និងសន្យាថាឈប់ប្រព្រឹត្តអំពើនេះទៀតហើយ។

- ជនជាប់ចោទឈ្មោះ [redacted] សិទ្ធ បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សូមតុលាការជួយសម្រាលទោសដល់ខ្លួនផង ខ្លួនបានដឹងកំហុស និងសន្យាថាឈប់ប្រព្រឹត្តអំពើនេះទៀតហើយ។

**ផ្អែកតាមកិច្ចពិភាក្សាដេញដោល**

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

ក្រោយពីបានពិនិត្យភស្តុតាងឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណា ត្រឹមត្រូវតាមច្បាប់

**យល់ឃើញថា**

១- តាមរយៈដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ១១៥៧ ពស.ព្រស/ឈ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) និងឈ្មោះ [redacted] សិទ្ធ ទៅជំនុំជម្រះពីបទៈ នេសាទត្រីដោយប្រើឧបករណ៍ឆក់ ប្រព្រឹត្តនៅចំណុច

និយាមកាកោះត្រឡាច ភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៨ ចំណុច ៤ នៃច្បាប់ស្តីពីជលផល។

២- តាមកំណត់ហេតុនៃបទល្មើសជលផលលេខៈ ១០ ខជ.សរ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៣ របស់ខណ្ឌរដ្ឋបាលជលផលសៀមរាប បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) និងឈ្មោះ [redacted] សិទ្ធ ពិតជាបានធ្វើសកម្មភាពនេសាទត្រីដោយប្រើឧបករណ៍ឆក់ ប្រព្រឹត្តនៅចំណុចនិយាមកាកោះត្រឡាច ភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ប្រាកដមែន។

៣- ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) និងឈ្មោះ [redacted] សិទ្ធ មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សី និងឯកសារភស្តុតាងដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងវត្ថុតាងដកហូតបានជាក់ស្តែងបង្ហាញឲ្យឃើញថា៖ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ១រំលងអាធ្រាត្រ ស្ថិតនៅចំណុចនិយាមកាកោះត្រឡាច ភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានករណីនេសាទត្រីដោយប្រើឧបករណ៍ឆក់ បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចាំ ភេទប្រុស អាយុ ៤៧ ឆ្នាំ និងឈ្មោះ [redacted] សិទ្ធ ភេទប្រុស អាយុ ២៧ ឆ្នាំ។ ក្រោយពីពួកគេបានឆក់ត្រីរួច បានជិះម៉ូតូត្រឡប់ទៅផ្ទះវិញក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងបានដកហូតនូវឧបករណ៍ឆក់ត្រីមួយចំនួនរួមមាន អាំងវែកទ័រឆក់ត្រីមានខ្សែភ្លើងចំនួន ០១ គ្រឿង, អាគុយ ៤០ អំពែចំនួន ០១ គ្រឿង, ត្រីឆក់បានចំនួន ៣គីឡូក្រាម និងម៉ូតូមួយគ្រឿងម៉ាក HONDA DREAM ស៊េរីឆ្នាំ២០១៣ ពណ៌ខ្មៅ ស្លាកលេខ សៀមរាប 1O-4197។ ក្រោយពីសមត្ថកិច្ចឃាត់ខ្លួន និងដកហូតវត្ថុតាងខាងលើនេះរួចមកសមត្ថកិច្ចបានសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាំ និងឈ្មោះ [redacted] សិទ្ធ បានឆ្លើយសារភាពថាពួកគេពិតជាបានទៅឆក់ត្រីនៅវេលាម៉ោង៨យប់ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ ស្ថិតនៅចំណុចទំនប់៧៨ ស្ថិតនៅភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប លុះដល់ម៉ោង១រំលងអាធ្រាត្រពួកគេបានត្រឡប់មកផ្ទះវិញ នៅពេលធ្វើដំណើរតាមផ្លូវក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងដកហូតវត្ថុតាងប្រាកដមែន។

៤- ជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) និងឈ្មោះ [redacted] សិទ្ធ មានចេតនាទុច្ចរិត ដោយបាននាំគ្នាធ្វើសកម្មភាពនេសាទត្រីដោយប្រើឧបករណ៍ឆក់ ដែលជាឧបករណ៍នេសាទដែលច្បាប់បានហាមឃាត់ ដែលអំពើនេះច្បាប់បញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌបទៈ នេសាទត្រីដោយប្រើឧបករណ៍ឆក់ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៨ ចំណុច ៤ នៃច្បាប់ស្តីពីជលផល ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ។

៥- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ៖ តម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ១៥៨ អយធ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ទុកជាបានការដដែល និងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថាការប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

Scanned with CamScanner

៦- សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងពីរនាក់ដែលបានស្នើសុំឲ្យតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនទាំង២នាក់ ដោយអនុវត្តទោសដាក់ពន្ធនាគារត្រឹម ៦ខែ និងព្យួរទោសនៅសល់ ឃើញថាការស្នើសុំនេះមានហេតុផលសមរម្យឲ្យតុលាការពិចារណាបាន តុលាការនឹងពិចារណាអំពីការសុំនេះ។

៧- ពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) និងឈ្មោះ [redacted] សិទ្ធ មានបញ្ហាខាងស្មារតីឡើយ ជនជាប់ចោទពិតជាបានយល់ដឹងពីផលវិបាកដែលកើតឡើងពីអំពើប្រព្រឹត្តរបស់ខ្លួន។

• *ក្រោយពីបានពិនិត្យពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថា* ៖

៨- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) និងឈ្មោះ [redacted] សិទ្ធ ពីបទៈ នេសាទត្រីដោយប្រើឧបករណ៍ឆក់ ប្រព្រឹត្តនៅចំណុចនិយាមកាកោះត្រឡាច ភូមិយុនមោយ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៨ ចំណុច ៤ នៃច្បាប់ស្តីពីជលផល។

៩- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) និងឈ្មោះ [redacted] សិទ្ធ ធ្វើឲ្យប៉ះពាល់ដល់ដល់ធនធានជលផល សន្តិសុខសណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋ។

១០- ជនជាប់ចោទឈ្មោះ [redacted] ចាំ (ជៀប ចាំ) និងឈ្មោះ [redacted] សិទ្ធ ទើបប្រព្រឹត្តបទមជ្ឈិមលើកទី១ ការរៀនសូត្របានតិចតួច ខ្វះការយល់ដឹង មានជីវភាពក្រីក្រ ហើយបានសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួន សន្យាថានឹងកែប្រែខ្លួនឈប់ប្រព្រឹត្តបទល្មើសនេសាទទៀតហើយ។ ហេតុនេះ គប្បីតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទទាំង២នេះ ដោយអនុវត្តទោសដាក់ពន្ធនាគារមួយផ្នែក និងសម្រេចព្យួរទោសដាក់ពន្ធនាគារមួយផ្នែកទៀតដែលនៅសល់ ស្របតាមមាត្រា ៩៣, មាត្រា ៩៤, មាត្រា ១០៤, មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

១១- វត្ថុតាងដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខៈ ៣០ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប មានដូចជា៖ អាគុយម៉ាក PINACO ពណ៌សលាយខ្មៅ ចំនួន១, អាំងវែកទ័រឆក់ចំនួន១, កាបូប ពណ៌ផ្កាឈូក ចំនួន១ គឺជាវត្ថុដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស តាមមាត្រា ៩៨ នៃច្បាប់ស្តីពីជលផល។

**<u>ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី</u>**

១- ផ្តន្ទាទោស៖

ក- ឈ្មោះ [redacted] **ចាំ** ([redacted] **ចាំ**) ភេទប្រុស អាយុ ៤៧ ឆ្នាំ (កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧២) ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៣ (**បី**) **ឆ្នាំ** ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេលកំណត់ **៦** (**ប្រាំមួយ**) **ខែ** ទោសដែលនៅសល់ត្រូវព្យួរ។



Scanned with CamScanner

ខ- ឈ្មោះ [redacted] សិទ្ធ ភេទប្រុស អាយុ ២៧ ឆ្នាំ (កើតថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៦) ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៣ (**បី**) **ឆ្នាំ ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល** កំណត់ **៦** (**ប្រាំមួយ**) **ខែ** ទោសដែលនៅសល់ត្រូវព្យួរ ។

ពីបទ: **នេសាទត្រីដោយប្រើឧបករណ៍ឆក់** ប្រព្រឹត្តនៅចំណុចនិយាមកាកោះគ្រឡាច ភូមិយុនមោយ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៨ ចំណុច ៤ នៃច្បាប់ស្តីពីជលផល។

២- វត្ថុតាងដូចមានក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ: ៣០ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប មានដូចជា៖ អាគុយម៉ាក PINACO ពណ៌សលាយខ្មៅ ចំនួន១, អាំងវែកទ័រឆក់ ចំនួន១, កាបូប ពណ៌ផ្កាឈូកចំនួន១ **សម្រេចរឹបអូស** តាមមាត្រា ៩៨ នៃច្បាប់ស្តីពីជលផល។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទទាំងពីរនាក់ ។

- ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ១១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
សៀមរាប ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី ១២ ខែ ៦ ឆ្នាំ២០២៣
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner